

# ចប់

## “ ឥទ្ធិពលសម្តី ”

គម្រោង TIGER ត្រូវបានអនុវត្តក្រោមកិច្ចសហការរបស់

vvob education for development

PKO PUTHI KOMAR ORGANISATION

# ឥទ្ធិពលសម្តី



រៀបចំដោយ

សហការឧបត្ថម្ភដោយ

Belgium partner in development

Flanders State of the Art

បោះពុម្ពផ្សាយដោយ៖

**© 2020 VVOB -** ការអប់រំដើម្បីការអភិវឌ្ឍន៍



Julien Dillensplein 1 bus 2A, 1060 Brussels, Belgium

ទូរស័ព្ទ៖ +32 2 209 07 99; គេហទំព័រ៖ www.vvob.org



**សិទ្ធិ និងការអនុញ្ញាត**

អ្នកនិពន្ធដែលទទួលខុសត្រូវ៖

Sven Rooms

© 2020 VVOB vzw

BY NC SA

កែសម្រួល និងរចនាដោយ GIM Publishing

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអាជ្ញាប័ណ្ណ:

Creative Commons Attribution-Non Commercial-Share Alike 4.0 International License

(CC BY-NC-SA 4.0)

ក្រោមអាជ្ញាបណ្ណនេះ អ្នកអាចថតចម្លង ចែកចាយ បញ្ជូន និងប្រែសម្រួលឯកសារនេះក្នុងន័យមិនរកកម្រៃ។ រាល់សំណួរដែលពាក់ព័ន្ធនឹងសិទ្ធិ និងអាជ្ញាបណ្ណខាងលើ សូមទំនាក់ទំនងសួរមកកាន់ការិយាល័យ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ តាមរយៈអាសយដ្ឋាន Julien Dillensplein 1 bus 2A, 1060 Brussels, Belgium - ទូរស័ព្ទ៖ +32 2 209 07 99; អ៊ីមែល៖ info@vvob.org; គេហទំព័រ៖ www.vvob.org

**ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ**

ឯកសារនេះ ត្រូវបានផលិតឡើងក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្វ្លែមីស៍។ ខ្លឹមសារនៃឯកសារនេះស្ថិតក្រោមការទទួលខុសត្រូវរបស់ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ទាំងនេះទេ។

សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្វ្លែមីស៍មិនទទួលខុសត្រូវចំពោះខ្លឹមសារនៅក្នុងឯកសារនេះទេ។



សហការឧបត្ថម្ភថវិកាដោយ៖

Belgium partner in development

Flanders State of the Art

ឯកសារនេះជាសមិទ្ធផលដែលចូលរួមសហការចងក្រងដោយ៖

vvob education for development

GADC

PUTHI KOMAR ORGANISATION






ថ្ងៃមួយ ពូភាបានទៅទទួលសុភាពពីសាលារៀន។ គាត់បានឮមិត្តភក្តិរបស់សុភាពជេរគ្នាទៅវិញទៅមក។ អ្នកខ្លះហៅគ្នាអាក្រក់ៗដូចជា មីកន្តើ អាខ្មៅ អាវែង អាស្វិត មីក្រញាញ់ មីស្រឡេវជាដើម។ ក្រោយពីឮដូច្នេះ គាត់មានអារម្មណ៍មិនល្អសោះ ព្រោះក្នុងគ្រួសារគាត់មិនដែលប្រើពាក្យបែបនេះទេ។ ក្រោយពីបានដឹងរឿងនេះ គាត់បានទៅពិភាក្សាជាមួយគ្រូបន្ទុកថ្នាក់របស់សុភាព។



ពេលពូភាបានទៅជួបនឹងអ្នកគ្រូបន្ទុកថ្នាក់របស់សុភាព ហើយបានលើកពីការប្រើប្រាស់ពាក្យសម្ដីរបស់កូនគាត់តាំងពីចូលរៀនមកប្លែកពីមុន ដោយនាងចេះជេរ ចេះប្រើពាក្យអសុរោះ ព្រមទាំងបានប្រាប់អ្នកគ្រូពីរឿងរ៉ាវដែលគាត់បានជួបប្រទះនៅថ្ងៃមកទទួលសុភាពពីសាលា។ គាត់ចង់ឱ្យអ្នកគ្រូជួយរកវិធីដោះស្រាយលើបញ្ហានេះ។



“ក្រោយពេលដឹងថា កូនសិស្សរបស់ខ្លួនប្រើពាក្យសម្ដីមិនសមរម្យ ហើយថែមទាំងមានការប្ដឹងពីអ្នកអាណាព្យាបាលផង ធ្វើឱ្យអ្នកគ្រូខឹងយ៉ាងខ្លាំង។ ពេលចូលរៀន អ្នកគ្រូបានស្ដីបន្ទោសឱ្យសិស្សទាំងនោះ ហើយបានគំរាមកំហែងសិស្សឱ្យឈប់ប្រើពាក្យសម្ដីមិនសមរម្យទាំងនោះ ជាហេតុធ្វើឱ្យសិស្សទាំងអស់មានការភ័យខ្លាចយ៉ាងខ្លាំង មិនហ៊ានទាំងមើលមុខអ្នកគ្រូផង។”



“ប៉ុន្តែថ្ងៃក្រោយមក ពួកគាត់នៅតែជេរគ្នា ដាក់ងារឱ្យគ្នា ឬបង្អាប់ថាម្នាក់នេះស្រឡាញ់ម្នាក់នោះដដែល ព្រោះអ្នកគ្រូក៏ប្រើពាក្យទាំងអស់នេះដែរ។ ដោយសារសីលធម៌របស់សិស្សនៅដដែល ជាហេតុជំរុញឱ្យសិស្សខ្លះប្រើប្រាស់អំពើហិង្សាដោះស្រាយបញ្ហាពេលមានទំនាស់ក្នុងសាលា។”



“ដោយបញ្ហាកាន់តែធំឡើងៗ គណៈគ្រប់គ្រងបានប្រជុំជាមួយលោកគ្រូ អ្នកគ្រូ ដើម្បីស្វែងរកដំណោះស្រាយ។ អង្គប្រជុំបានជំរុញឱ្យលោកគ្រូ អ្នកគ្រូទាំងអស់ប្រើពាក្យសម្ដីសមរម្យធ្វើជាគំរូដល់សិស្ស ។”



“គណៈគ្រប់គ្រងក៏នឹងលើកយកបញ្ហាសីលធម៌ទៅណែនាំសិស្សពេលគោរពទង់ជាតិ និងសរសេរពាក្យស្លោកទាក់ទងនឹងការប្រើពាក្យសម្ដីដាក់តាមទីធ្លាសាលា។ បន្ទាប់មកគណៈគ្រប់គ្រងក៏ឱ្យលោកគ្រូ អ្នកគ្រូស្វែងរកជំនួយពីព្រះសង្ឃក្នុងការអប់រំសិស្សឱ្យមានសីលធម៌។”



“

បន្ទាប់ពីលទ្ធផលសម្រេចនៅក្នុងអង្គប្រជុំមក នៅថ្ងៃសៅរ៍ នាចុងខែកុម្ភៈ សាលារៀនបានរៀបចំពិធីបុណ្យផ្កាប្រាក់ដើម្បីរៃលុយកសាងរបងសាលា។ ពេលនោះ គណៈគ្រប់គ្រងបាននិមន្តព្រះសង្ឃមកសម្តែងព្រះធម៌ទេសនាដើម្បីអប់រំដល់សិស្សទាំងអស់ក្នុងសាលាពីបញ្ហាសីលធម៌រស់នៅ។ ទង្វើនេះបានធ្វើឱ្យឥរិយាបថសិស្ស លោកគ្រូ អ្នកគ្រូបានផ្លាស់ប្តូរមករកភាពល្អប្រសើរ និងមានសេចក្តីថ្លៃថ្នូរវិញ។

”



“ក្រៅពីនេះ សាលាបានបន្តផ្សព្វផ្សាយពីការប្រើប្រាស់ភាសាដែលឆ្លើយតបនឹងសមភាពយេនឌ័រទៅកាន់អ្នកពាក់ព័ន្ធនៅតាមទីសាធារណៈជាដើម។ ចាប់តាំងពីពេលនោះមក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ក៏ដូចជាអ្នកអាណាព្យាបាលបានដឹង និងនាំគ្នាប្រើប្រាស់ពាក្យសម្ដីល្អៗចំពោះគ្នាទៅវិញទៅមក ដើម្បីបង្កើតជាភាតរភាពក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។”

